ក្រុមហ៊ុនធានារ៉ាប់រង កម្ពុជាឡុនប៉ាក់

CAMPU LONPAC INSURANCE 柬埔寨大众伦平保险

**តារាងព័ត៌មានអំពីផលិតផល**

(សូមមេត្តាអានតារាងព័ត៌មានអំពីផលិតផលមុនពេលលោកអ្នកសម្រេចចិត្តទិញធានារ៉ាប់រងលើភោជនីយដ្ឋាន ។ សូមមេត្តាអានផងដែរនូវខចែង និងលក្ខខណ្ឌទូទៅដែលមាននៅក្នុងកិច្ចសន្យា)

# ការធានារ៉ាប់រងលើភោជនីយដ្ឋាន

## ១. តើផលិតផលធានារ៉ាប់រងនេះជាអ្វី?

កិច្ចសន្យាធានារ៉ាប់រងនេះផ្តល់នូវការធានារ៉ាប់រងយ៉ាងទូលំទូលាយលើទ្រព្យសម្បត្តិ ការទទួលខុសត្រូវ និងបុគ្គលិកដែលបំរើការងារក្នុងសហគ្រាសរបស់លោកអ្នកពីហានិភ័យអាជីវកម្មដូចជា ការបាត់បង់ ឬការខូចខាតចំពោះទ្រព្យសម្បត្តិក្នុងករណីដែលមានគ្រោះថ្នាក់ជាយថាហេតុ គ្រោះមហន្តរាយ ឬហេតុការណ៍អាក្រក់ផ្សេងៗ ការទទួលខុសត្រូវតាមផ្លូវច្បាប់ និងគ្រោះថ្នាក់ដែលបណ្តាលអោយរបួសលើរាងកាយ ។

## ២. តើការធានារ៉ាប់រងនេះផ្តល់នូវការធានា ឬអត្ថប្រយោជន៍អ្វីខ្លះ?

ផលិតផលនេះផ្តល់ជូនលោកអ្នកនូវសេរីភាពក្នុងការជ្រើសរើស និងរួមបញ្ចូលនូវកាតព្វកិច្ចធានារ៉ាប់រងជាមូលដ្ឋានរបស់លោកអ្នកសំរាប់អគ្គិភ័យ និងហានិភ័យផ្សេងៗ និងការធានារ៉ាប់រងគ្រោះថ្នាក់ចំពោះនិយោជិតដោយមានលំដាប់នៃការធានារ៉ាប់រងតែមួយដែលសមស្របសំរាប់ថវិការ និងតម្រូវការការពាររបស់លោកអ្នកដោយមានរយៈពេលផុតកំណត់តែមួយ ។

| ផ្នែក | ប្រភេទនៃការធានារ៉ាប់រង | វិសាលភាពនៃការធានារ៉ាប់រង |
|---|---|---|
| **I. ការធានារ៉ាប់រងជាមូលដ្ឋាន (ជាកាតព្វកិច្ច)** | **ការធានារ៉ាប់រងលើអគ្គិភ័យ និងហានិភ័យផ្សេងៗ** | ធ្វើសំណងចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រងសំរាប់ការបាត់បង់ ឬការខូចខាតចំពោះទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងដែលបង្កឡើងដោយអគ្គិភ័យ រន្ទះ និង ហានិភ័យបន្ថែមផ្សេងៗទៀត ។ |
| | **ការធានារ៉ាប់រងលើគ្រោះថ្នាក់ចំពោះកម្មករនិយោជិត** | ការទទួលខុសត្រូវចំពោះមរណៈភាព និងពិការភាពជាអចិន្ត្រៃយ៍ដែលបណ្តាលមកពីគ្រោះថ្នាក់កើតឡើងក្នុងប្រទេសកម្ពុជា ។ |
| **II. ការធានារ៉ាប់រងបន្ថែម (ជាជម្រើស)** | **ការធានារ៉ាប់រងលើការទទួលខុសត្រូវជាសាធារណៈ** | ធ្វើសំណងចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រងសំរាប់ការទទួលខុសត្រូវស្របច្បាប់ចំពោះគ្រោះថ្នាក់ដែលបង្កឡើងដោយ ឬតាមរយៈការធ្វេសប្រហែសរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬបុគ្គលដែលបម្រើការងារអោយបុគ្គលដែលត្រូវបានធានារ៉ាប់រងក្នុងអំឡុងពេលបំពេញការងារក្នុងបរិវេណអាជីវកម្ម ។ |
| | **ការធានារ៉ាប់រងលើអំពើចោរកម្ម** | ធ្វើសំណងចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រងសំរាប់ការបាត់បង់ដែលបណ្តាលមកពីអំពើចោរកម្ម ឬអំពើប្លន់ខណៈពេលដែលទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងត្រូវបានរក្សាទុកក្នុងបរិវេណអគារដែលត្រូវបានធានារ៉ាប់រង ។ *(ចំណាំ: ការធានានេះគឺអនុវត្តតែចំពោះទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងក្នុងផ្នែកទី I ការធានារ៉ាប់រងលើអគ្គិភ័យ និងហានិភ័យផ្សេងៗតែប៉ុណ្ណោះ)* ។ |
| **II. ការធានារ៉ាប់រងបន្ថែម (ជាជម្រើស) "ត"** | **ការធានារ៉ាប់រងលើរូបិយវត្ថុក្នុងបរិវេណអគារ** | ធ្វើសំណងចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រងសំរាប់ការបាត់បង់ប្រាក់កាសដែលបណ្តាលមកពីមូលហេតុផ្សេងៗដែលមិនមានបញ្ជាក់នៅក្នុងករណីលើកលែង ខណៈដែលប្រាក់កាសទាំងនោះត្រូវបានរក្សាទុកក្នុងបរិវេណអគារដែលត្រូវបានធានារ៉ាប់រង ។ |
| | **ការធានារ៉ាប់រងលើការដឹកជញ្ជូនរូបិយវត្ថុ** | ធ្វើសំណងចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រងសំរាប់ការបាត់បង់ប្រាក់កាសដែលបណ្តាលមកពីមូលហេតុផ្សេងៗដែលមិនមានបញ្ជាក់នៅក្នុងករណីលើកលែង ខណៈដែលប្រាក់កាសទាំងនោះត្រូវបានដឹកជញ្ជូនក្នុងប្រទេសកម្ពុជា ។ |
| **ឥតគិតថ្លៃ** | **ការធានារ៉ាប់រងលើគ្រោះថ្នាក់បុគ្គល** | ការទទួលខុសត្រូវចំពោះមរណៈភាព និងពិការភាពជាអចិន្ត្រៃយ៍ដោយសារគ្រោះថ្នាក់ផ្សេងៗដែលកើតឡើងគ្រប់ទីកន្លែងលើពិភពលោក ។ |

*ចំណាំ: សូមមេត្តាពិនិត្យមើលក្នុងកិច្ចសន្យាធានារ៉ាប់រងនេះសំរាប់តារាងលម្អិតអំពីខចែង និងលក្ខខណ្ឌផ្សេងៗដែលមាននៅក្នុងកិច្ចសន្យា ។*

## ៣. តើមានការបន្ថែមនូវតំលៃពិសេសណាមួយដែរឬទេ?

**ផ្តល់ជូនការធានាដោយឥតគិតថ្លៃ**

ពិតជាមានការផ្តល់ជូននូវការធានារ៉ាប់រងបន្ថែមដោយឥតគិតថ្លៃ ប្រសិនបើលោកអ្នកជ្រើសរើសយកផ្នែក II. ការធានារ៉ាប់រងបន្ថែម

**ការធានារ៉ាប់រងលើគ្រោះថ្នាក់បុគ្គល**

- ផ្តល់ជូននូវការធានារ៉ាប់រងសំរាប់លោកអ្នក ឬម្ចាស់ភាគហ៊ុនក្នុងអាជីវកម្មរបស់លោកអ្នកចំពោះមរណៈភាព ឬពិការភាពជាអចិន្ត្រៃយ៍ដែលបណ្តាលមកពីគ្រោះថ្នាក់កើតឡើង២៤ម៉ោងគ្រប់ទីកន្លែងលើពិភពលោក ។

## ៤. តើចំនួនបុព្វលាភធានារ៉ាប់រងប៉ុន្មានដែលខ្ញុំត្រូវបង់?

ចំនួនបុព្វលាភធានារ៉ាប់រងសរុបដែលលោកអ្នកត្រូវបង់អាចមានភាពខុសគ្នាអាស្រ័យលើចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង តម្រូវការធានារ៉ាប់រងបន្ថែម និងដោយសារតម្រូវការពីផ្នែកចេញប័ណ្ណធានារ៉ាប់រងរបស់ក្រុមហ៊ុនយើងខ្ញុំ ។

**ផ្នែកទី I: ការធានារ៉ាប់រងជាមូលដ្ឋាន (ជាកាតព្វកិច្ច)**

| វិសាលភាពនៃការធានារ៉ាប់រង | ចំនួនទឹកប្រាក់ដែលត្រូវធានារ៉ាប់រង |
|---|---|
| **អគ្គិភ័យ និងហានិភ័យផ្សេងៗ** | តំលៃធានារ៉ាប់រងសរុប : ត្រូវបានកំណត់ដោយខ្លួនលោកអ្នកផ្ទាល់រហូតដល់ចំនួនទឹកប្រាក់អតិបរមា ១.០០០.០០០ ដុល្លារ |
| **គ្រោះថ្នាក់ចំពោះកម្មករនិយោជិត** | បុគ្គលិកចំនួន៣នាក់ - មរណៈភាព និងពិការភាពជាអចិន្ត្រៃយ៍ ១.០០០ ដុល្លារ សំរាប់បុគ្គលិកម្នាក់ |
| **បុព្វលាភធានារ៉ាប់រងជាមូលដ្ឋានប្រចាំឆ្នាំ** | ចំនួនទឹកប្រាក់អប្បបរមា ៦៥ ដុល្លារ |

** ហានិភ័យដែលបានផ្តល់ជូន: ការផ្ទុះសម្ភារៈក្នុងផ្ទះ ព្យុះភ្លៀង ការខូចខាតដោយសារទឹក និងផ្សេងៗដែលបង្កឡើងដោយសារអគ្គិភ័យ ។*

### ផ្នែកទី II: ការធានារ៉ាប់រងបន្ថែម (ជាជម្រើស)

| វិសាលភាពនៃការធានារ៉ាប់រង | ដែនកំណត់នៃការទទួលខុសត្រូវ |
|---|---|
| ការទទួលខុសត្រូវជាសាធារណៈ | ៧៥.០០០ ដុល្លារ |
| អំពើចោរកម្ម | ៥.០០០ ដុល្លារ |
| រូបិយវត្ថុក្នុងបរិវេណអគារ | ១.០០០ ដុល្លារ |
| ការដឹកជញ្ជូនរូបិយវត្ថុ | ១.០០០ ដុល្លារ |
| ផ្តល់ជូននូវការធានារ៉ាប់រងដោយឥតគិតថ្លៃសំរាប់ផ្នែកទី II: ការធានារ៉ាប់រងបន្ថែម | |
| គ្រោះថ្នាក់បុគ្គល<br>- សំរាប់បុគ្គលដែលត្រូវបានធានារ៉ាប់រងម្នាក់ | ២.៥០០ ដុល្លារ |
| បុព្វលាភបន្ថែមប្រចាំឆ្នាំ (ផ្នែកទី I និងទី II) | ២២០ ដុល្លារ |

** ត្រូវអនុវត្តនូវខចែង និងលក្ខខណ្ឌផ្សេងៗ*

## ៥. តើខ្ញុំអាចបន្ថែមនូវចំនួនទឹកប្រាក់ដែលត្រូវធានារ៉ាប់រង និងដែនកំណត់នៃការទទួលខុសត្រូវបានដែរឬទេ?

បាន

<u>ឧទាហរណ៍:</u>

### ផ្នែកទី I : ការធានារ៉ាប់រងជាមូលដ្ឋានសម្រាប់ភោជនីយដ្ឋាន

| វិសាលភាពនៃការធានារ៉ាប់រង | កម្មវត្ថុនៃការធានារ៉ាប់រង | ចំនួនទឹកប្រាក់ដែលត្រូវធានារ៉ាប់រង (ការធានារ៉ាប់រងជាមូលដ្ឋាន) | អត្រាបុព្វលាភបន្ថែម | តំលៃធានារ៉ាប់រងបន្ថែម / កម្មករនិយោជិត | បុព្វលាភបន្ថែម |
|---|---|---|---|---|---|
| អគ្គិភ័យ | ក. អគារ | ២៥.០០០ ដុល្លារ | ០.១២៩% | ៥០.០០០ ដុល្លារ | ៦៤.៥០ ដុល្លារ |
| | ខ. ការកែលំអរអគារ និងទ្រព្យសម្បត្តិផ្សេងៗរាប់បញ្ចូលទាំងសន្និធិ | ១០.០០០ ដុល្លារ | ០.១២៩% | ២០.០០០ ដុល្លារ | ២៥.៨០ ដុល្លារ |
| គ្រោះថ្នាក់ចំពោះកម្មករនិយោជិត | សម្រាប់កម្មករនិយោជិត ៣នាក់ | ១.០០០ ដុល្លារ | ៦.៥០ ដុល្លារ សំរាប់កម្មករនិយោជិតម្នាក់ៗ | បន្ថែមកម្មករនិយោជិតចំនួន៣នាក់ | ១៩.៥០ ដុល្លារ |
| | | | | បុព្វលាភសម្រាប់ការធានារ៉ាប់រងបន្ថែម | ១០៩.៨០ ដុល្លារ |

### ផ្នែកទី II : ការធានារ៉ាប់រងបន្ថែមសំរាប់ភោជនីយដ្ឋាន

| វិសាលភាពនៃការធានារ៉ាប់រង | ដែនកំណត់នៃការទទួលខុសត្រូវ | អត្រាបុព្វលាភបន្ថែម | ការបន្ថែមលើដែនកំណត់នៃការទទួលខុសត្រូវ | បុព្វលាភបន្ថែម |
|---|---|---|---|---|
| ការទទួលខុសត្រូវជាសាធារណៈ | ៧៥.០០០ ដុល្លារ | ១០ ដុល្លារ សំរាប់រាល់ការបន្ថែមចំនួនទឹកប្រាក់ ១០.០០០ ដុល្លារ | ៥០.០០០ ដុល្លារ | ៥០ ដុល្លារ |
| អំពើចោរកម្ម | ៥.០០០ ដុល្លារ | ០.៥០% | ៥.០០០ ដុល្លារ | ២៥ ដុល្លារ |
| រូបិយវត្ថុក្នុងបរិវេណអគារ | ១.០០០ ដុល្លារ | ២% | ៤.០០០ ដុល្លារ | ៨០ ដុល្លារ |
| ការដឹកជញ្ជូនរូបិយវត្ថុ | ១.០០០ ដុល្លារ | ១% | មិនកំណត់ | គ្មាន |
| | | | បុព្វលាភសំរាប់ការធានារ៉ាប់រងបន្ថែម | ១៥៥ ដុល្លារ |

### តារាងសង្ខេបអំពីបុព្វលាភប្រចាំឆ្នាំសម្រាប់ផ្នែកទី I និងទី II

| ផ្នែក | បុព្វលាភអប្បបរមា | បុព្វលាភបន្ថែម | បុព្វលាភប្រចាំឆ្នាំសរុប |
|---|---|---|---|
| ១. ការធានារ៉ាប់រងជាមូលដ្ឋានបូកនឹង | ២២០ ដុល្លារ | ១០៩.៨០ ដុល្លារ | ៤៨៤.៨០ ដុល្លារ |
| ២. ការធានារ៉ាប់រងបន្ថែម | | ១៥៥ ដុល្លារ | |

## ៦. តើខ្ញុំអាចបង្កើននូវចំនួនទឹកប្រាក់ដែលត្រូវធានារ៉ាប់រងជាអតិបរមា/ដែនកំណត់នៃការទទួលខុសត្រូវបានចំនួនប៉ុន្មាន?

| វិសាលភាពនៃការធានារ៉ាប់រង | ចំនួនទឹកប្រាក់ដែលត្រូវធានារ៉ាប់រងជាអតិបរមា/ដែនកំណត់នៃការទទួលខុសត្រូវ |
|---|---|
| អគ្គិភ័យ | ១.០០០.០០០ ដុល្លារ |
| គ្រោះថ្នាក់ចំពោះកម្មករនិយោជិត | មិនមានការកំណត់លើចំនួននិយោជិត |
| ការទទួលខុសត្រូវជាសាធារណៈ | ៥០០.០០០ ដុល្លារ |
| អំពើចោរកម្ម/រូបិយវត្ថុក្នុងបរិវេណអគារ/ ការដឹកជញ្ជូនរូបិយវត្ថុ | ដោយផ្អែកលើការសម្រេចចិត្តរបស់ក្រុមហ៊ុនធានារ៉ាប់រង |

## ៧. តើខ្ញុំត្រូវបង់បុព្វលាភធានារ៉ាប់រងយ៉ាងដូចម្តេច និងដោយវិធីណា?

នេះគឺជាកិច្ចសន្យាដែលមានរយៈពេលពេញមួយឆ្នាំហើយលោកអ្នកអាចជ្រើសរើសយកការបង់បុព្វលាភធានារ៉ាប់រងតាមរយៈសាច់ប្រាក់ មូលប្បទានប័ត្រ ឬតាមរយៈប័ណ្ណឥណទាន។

## ៨. តើមានលក្ខខណ្ឌ និងខចែងសំខាន់ៗអ្វីខ្លះដែលខ្ញុំគួរតែដឹង?

- កាតព្វកិច្ចក្នុងការផ្តល់ព័តិមាន
  - លោកអ្នកត្រូវផ្តល់ព័តិមានពិតប្រាកដទាំងឡាយដែលលោកអ្នកដឹង ឬគួរតែដឹង។ លោកអ្នកត្រូវប្រាកដថាទំរង់បែបបទស្នើសុំការធានារ៉ាប់រងត្រូវបានបំពេញដោយត្រឹមត្រូវ ពីព្រោះវានឹងក្លាយទៅជាមូលដ្ឋានគ្រឹះនៃកិច្ចសន្យាធានារ៉ាប់រង។
- ចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង
  - លោកអ្នកត្រូវប្រាកដថាទ្រព្យសម្បត្តិរបស់លោកអ្នកត្រូវបានធានារ៉ាប់រងក្នុងចំនួនទឹកប្រាក់មួយសមស្របដោយបូកបន្ថែមនូវថ្លៃកែលំអរផ្សេងៗ។
- បណ្តឹងទាមទារសំណង
  - ក្នុងករណីមានគ្រោះថ្នាក់ដែលបណ្តាលអោយមានបណ្តឹងទាមទារសំណងកើតឡើង លោកអ្នកត្រូវជូនព័តិមានមកក្រុមហ៊ុនយើងខ្ញុំក្នុងរយៈពេល១៤ថ្ងៃ។

## ៩. តើកិច្ចសន្យាធានារ៉ាប់រងនេះមានករណីលើកលែងសំខាន់ៗអ្វីខ្លះ?

ដូចកិច្ចសន្យាធានារ៉ាប់រងផ្សេងៗទៀតដែរ កិច្ចសន្យាធានារ៉ាប់រងនេះមានករណីលើកលែងទូទៅដូចជាសង្គ្រាម ភេរវកម្ម សញ្ញាវុធនុយក្លេអ៊ែ និងសារធាតុវិទ្យុសកម្ម ដែលករណីលើកលែងទាំងនេះត្រូវបានអនុវត្តចំពោះគ្រប់កិច្ចសន្យាធានារ៉ាប់រងទាំងអស់ដែលស្ថិតនៅក្រោមការធានារ៉ាប់រងជាកញ្ចប់។

ខាងក្រោមនេះគឺជាករណីលើកលែងសំខាន់ៗសំរាប់ប្រភេទនៃការធានារ៉ាប់រងនីមួយៗដែលស្ថិតនៅក្នុងការធានារ៉ាប់រងជាកញ្ចប់:

- **អគ្គិភ័យ**
  - ការបាត់បង់ ឬការខូចខាតប្រសិនបើទ្រព្យសម្បត្តិត្រូវបានទុកទំនេរចោលលើសពី៣០ថ្ងៃបន្តបន្ទាប់គ្នា។
- **ការទទួលខុសត្រូវជាសាធារណៈ**
  - របួស ជំងឺ ការបាត់បង់ ឬខូចខាតដែលជាលទ្ធផលបណ្តាលមកពីសកម្មភាពនៃសេចក្តីសម្រេច ឬការភ្លេចភ្លាំងរបស់លោកអ្នក។
  - ការពិន័យជាប្រាក់ ទោសបញ្ញត្តិ ការដាក់ទណ្ឌកម្ម។
- **អំពើចោរកម្ម**
  - ការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពីអំពើចោរកម្មដែលបង្កឡើងដោយកម្មករនិយោជិតរបស់លោកអ្នក ឬបុគ្គលណាមួយដែលរស់នៅស្របច្បាប់ក្នុងបរិវេណអគារ។
  - ការបាត់បង់ ឬការខូចខាតប្រសិនបើបរិវេណអគារត្រូវបានទុកទំនេរចោលលើសពី៣០ថ្ងៃបន្តបន្ទាប់គ្នា។
- **រូបិយវត្ថុក្នុងបរិវេណអគារ ឬការដឹកជញ្ជូនរូបិយវត្ថុ**
  - ការភ្លេចភ្លាំង ឬកំហុសឆ្គងផ្នែកគណនេយ្យក្នុងស្ថានភាពដែលមិនអាចពន្យល់បកស្រាយបាន ការកាត់រំលស់តំលៃ និងការខាតបង់ផ្នែកហិរញ្ញវត្ថុ។
  - ការបាត់បង់ពីយានយន្តដែលទុកចោលដោយគ្មានការយាមកាម ឬតាមរយៈការប្រើប្រាស់កូនសោរ លុះត្រាការប្រើប្រាស់កូនសោរនោះតាមរយៈការប្រើកំលាំង ឬគំរាមកំហែង។
- **គ្រោះថ្នាក់បុគ្គល**
  - ការធ្វើអត្តឃាត ឬការបង្ករបួសលើរាងកាយដោយខ្លួនឯង ជំងឺគ្រប់ប្រភេទ ជំងឺអេដស៍ កីឡាអាជីព និងកីឡាប្រកបដោយគ្រោះថ្នាក់ និងបណ្តឹងទាមទារសំណងដែលទាក់ទងនឹងការមានគត៌។

*ចំណាំ : ករណីលើកលែងក្នុងតារាងខាងលើនេះមិនទាន់អស់នៅឡើយទេ។ សូមមេត្តាពិនិត្យមើលក្នុងកិច្ចសន្យាធានារ៉ាប់រងសំរាប់តារាងលំអិតអំពីករណីលើកលែងផ្សេងទៀតដែលមាននៅក្នុងកិច្ចសន្យា នេះ។*

## ១០. តើមានករណីលើកលែងចំពោះហានិភ័យ/ ប្រភេទអាជីវកម្មណាមួយដែលខ្ញុំគួរតែដឹងដែរឬទេ?

ហានិភ័យ/ប្រភេទអាជីវកម្មដូចខាងក្រោមនេះមិនត្រូវបានធានាដោយកិច្ចសន្យាធានារ៉ាប់រងនេះឡើយ:

រោងចក្រ ឬសហគ្រាសផលិតការ៉ូ សួនកំសាន្ត/កន្លែងផ្លូវដើរ/មជ្ឈមណ្ឌលកំសាន្ត (សាលល្បែងប៊ីយ៉ា មជ្ឈមណ្ឌលស្ពុកយ៉រ ក្លឹបរាត្រី បានីយដ្ឋាន តៀមស្រា កន្លែងឌីស្កូ សាលតន្ត្រី និងរបាំ) សិល្បៈអ្នកចែកចាយវត្ថុបុរាណ និងវត្ថុកម្រ អ្នកចែកចាយ និងលក់រាយនូវនាឡិកា រោងចក្រឬសហគ្រាសផលិតទាន ក្រមួន និងសម្ភារៈសំរាប់ខាត់អោយភ្លឺរលោង សហគ្រាសផលិតធ្យូង អ្នកចែកចាយនិងលក់រាយនូវស៊ីហ្គារ/បារី ភោជនីយដ្ឋានដែលមានទំហំតូច និងមិនស្របច្បាប់ដែលមានសេវ៉ាអ៊ិនធឺណេត កន្លែងបិតស្រា រោងចក្រ និងឃ្លាំងផ្ទុកសារធាតុគីមីដែលអាចឆេះ/ផ្ទុះ ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារ រោងចក្រផលិតហ្វូម មជ្ឈមណ្ឌលល្បែងស៊ីសង/ហាងភ្នាល់ល្បែង អ្នកទទួលបញ្ចាំ ឬចែកចាយលក់គ្រឿងអលង្ការ/ត្បូង/មាស/ប្រាក់/លោហៈធាតុមានតំលៃ/អ្នកផ្តល់កម្ចី/អ្នកប្តូរប្រាក់/អ្នកដឹកជញ្ជូនប្រាក់/អ្នកទាបំណុល/ទីផ្សារមូលប័ត្រ/តូបលក់ប្រេងសាំង ឱសថស្ថាន និងឧស្សាហកម្មដែលពាក់ព័ន្ធនឹងជីវបច្ចេកវិជ្ជា អ្នកចែកចាយ ឬលក់រាយនូវទំនិញសំរាប់បម្រុងទុក (រាប់បញ្ចូលទាំងម្ហូបអាហារក្រៀមឬស្ងួតដែលមានតំលៃ ដូចជាព្រុយត្រីឆ្លាម ខ្យងសមុទ្រ និងប្រភេទស្រដៀងគ្នានេះ) កន្លែងយកថ្ម មជ្ឈមណ្ឌល ឬរោងចក្រធ្វើនិស្សរណកម្ម រោងម៉ាស៊ីនកិនស្រូវ កន្លែងជួសជុល/ផលិតនាវ៉ា អ្នកចែកចាយ ឬលក់រាយនូវផលិតផលស្រាដែលមានជាតិអាល់កុលក្នុងកំរិតខ្ពស់ ហានិភ័យទាក់ទងនឹងការងារជាងឈើ ព្រមទាំងហានិភ័យទាក់ទងនឹងការធ្វើគ្រឿងសង្ហារឹម រោងចក្រផលិតផលប្លាស្ទិក។

## ១១. តើមានលក្ខខណ្ឌព្រមព្រៀងជាមុនសំរាប់ផលិតផលនេះដែរឬទេ?

- មិនមានបណ្តឹងទាមទារសំណងកើតឡើងក្នុងរយៈពេល៣ឆ្នាំ (មិនអនុវត្តចំពោះអាជីវកម្មដែលទើបបង្កើតថ្មី)
- អគារត្រូវបានកាន់កាប់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងតែម្នាក់គត់
- អគារសាងសង់ឡើងពីឥដ្ឋ ក្បឿង សំណង់ធ្វើពីបេតុង
- គ្មានសកម្មភាពបាញ់ថ្នាំក្នុងបរិវេណអគារ
- បុគ្គលដែលត្រូវបានធានារ៉ាប់រងមិនធ្លាប់ទទួលនូវការបដិសេធ លុបចោល ឬច្រានចោលនូវការធានារ៉ាប់រងពីមុន។

## ១២. តើខ្ញុំអាចដាក់ពាក្យស្នើសុំការធានារ៉ាប់រងនេះដោយវិធីណា?

លោកអ្នកអាចដាក់ពាក្យស្នើសុំការធានារ៉ាប់រងនេះតាមរយៈការិយាល័យរបស់ក្រុមហ៊ុនធានារ៉ាប់រងកម្ពុឡុនប៉ាក។

## ១៣. តើខ្ញុំអាចលុបចោលនូវកិច្ចសន្យាធានារ៉ាប់រងបានដែរឬទេ?

លោកអ្នកអាចលុបចោលនូវកិច្ចសន្យាធានារ៉ាប់រងនេះបានគ្រប់ពេលដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់ក្រុមហ៊ុនយើងខ្ញុំ។ ដោយផ្អែកលើការធ្វើមោឃភាពនៃកិច្ចសន្យានេះ លោកអ្នកមានសិទ្ធិទទួលបាននូវបុព្វលាភធានារ៉ាប់រងវិញដោយផ្អែកលើរយៈពេលនៃការធានារ៉ាប់រងដែលនៅមានសុពលភាពដក១០%នៃថ្លៃចំណាយរដ្ឋបាល។

## ១៤. តើខ្ញុំត្រូវធ្វើយ៉ាងដូចម្តេចប្រសិនបើមានការផ្លាស់ប្តូរនូវអាស័យដ្ឋានទំនាក់ទំនង ឬព័តិមានលម្អិតដ៏ទៃទៀតដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រង?

វាមានសារៈសំខាន់ក្នុងការផ្តល់ព័តិមានជាបន្ទាន់មកក្រុមហ៊ុនយើងខ្ញុំ ប្រសិនបើមានការផ្លាស់ប្តូរផ្សេងៗដែលពាក់ព័ន្ធនឹងកិច្ចសន្យាធានារ៉ាប់រងរបស់លោកអ្នកដើម្បីធានាថាគ្រប់ព័តិមានលម្អិត និង អាស័យ-ដ្ឋានទំនាក់ទំនងត្រូវបានកត់ត្រាជាថ្មីនៅក្នុងឯកសាររបស់ក្រុមហ៊ុនយើងខ្ញុំ។

## ១៥. តើខ្ញុំអាចទទួលបានព័តិមានលម្អិតជាងនេះទៀតពីកន្លែងណា?

ប្រសិនបើលោកអ្នកមានចម្ងល់ផ្សេងៗ សូមមេត្តាទាក់ទងមកក្រុមហ៊ុនយើងខ្ញុំតាមរយៈអាស័យដ្ឋានដូចខាងក្រោម :


**ផ្នែកបំរើអតិថិជន**
**ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក**
**ជាន់ទី៧ នៃអគារកម្ពុប៊ែង**
**អគារលេខ២៣ ផ្លូវលេខ១១៤**
**ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
**ទូរស័ព្ទលេខ : ០២៣ ៥៦៦ ៥៦៦**
**ទូរសារលេខ : ០២៣ ៥៨៦ ៣០៨**
**អ៊ីមែល : enquiries@campulonpac.com.kh**
**គេហទំព័រ : www.campulonpac.com.kh**


## ១៦. មានប្រភេទនៃការធានារ៉ាប់រងផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះ

ប្រភេទនៃការធានារ៉ាប់រងនីមួយៗអាចត្រូវបានលក់ជាលក្ខណៈបុគ្គលដោយផ្អែកលើលក្ខខណ្ឌនិងខចែងដែលមាននៅក្នុងប្រភេទនៃការធានារ៉ាប់រងនីមួយៗ។

**កំណត់ចំណាំពិសេស:**

**លោកអ្នកត្រូវប្រាកដថាទ្រព្យសម្បត្តិរបស់លោកអ្នកដែលត្រូវបានធានារ៉ាប់រងនូវចំនួនទឹកប្រាក់សមស្រប។ លោកអ្នកគួរតែអាន និងស្វែងយល់នូវកិច្ចសន្យាធានារ៉ាប់រងនេះ និង ពិភាក្សាដោយផ្ទាល់ជាមួយក្រុមហ៊ុនយើងខ្ញុំសំរាប់ព័តិមានលម្អិតផ្សេងៗទៀត។**

**ព័តិមានដែលផ្តល់ជូននៅក្នុងតារាងនេះមានសុពលភាពចាប់ពី ០១.១២.២០១១**

ចំណាំ: សំរាប់លក្ខខណ្ឌ និងខចែងជាក់លាក់ សូមមេត្តាពិនិត្យមើលនៅក្នុងកិច្ចសន្យារបស់ក្រុមហ៊ុនយើងខ្ញុំ។